ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ០៨/០៩ —ក្លូប៉ល អាប៉ារែល**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

**ភាគីនៃវិវាទ**

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ក្លូប៉ល អាប៉ារែល លីមីធីត**

អាសយដ្ឋាន : ភូមិត្រពាំងទួល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៩៤៦ ០៤៥ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក វី វ៉ាន់ឡូ ប្រធានធនធានមនុស្សស្តីទី

២- លោក រឿន វណ្ណារ៉ា មន្ត្រីសម្របសម្រួល

**២- ភាគីកម្មករនិយោជិត**

**ក-ឈ្មោះ : សហព័ន្ធសហជីព-សហជីពខ្មែរ នៃរោងចក្រកាត់ដេរ ក្លូប៉ល អាប៉ារែល**

អាសយដ្ឋាន : ភូមិត្រពាំងរនាម ស្រុកអង្គស្នួល ខេត្តកណ្តាល

លេខទូរស័ព្ទ : ០១២ ៦៥៨ ១២៩ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ជួន មុំថុល ប្រធានសហព័ន្ធសហជីពខ្មែរ

មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

២- លោក ម៉ុម ធន  មន្ត្រីដោះស្រាយវិវាទសហព័ន្ធសហជីពខ្មែរ

៣- លោក ញ៉ូវ សារឿន  ប្រធានសហជីពខ្មែរ ប្រចាំក្រុមហ៊ុន ក្លូប័ល អាប៉ារែល

៤- លោក ទូច ផល្លី  អនុប្រធានសហជីពខ្មែរ ប្រចាំក្រុមហ៊ុន ក្លូប័ល អាប៉ារែល

**ខ-ឈ្មោះ : សហព័ន្ធសហជីព-សហជីពឯករាជ្យ និងប្រជាធិបតេយ្យ នៃរោងចក្រ ក្លូប័ល អាប៉ារែល**

អាសយដ្ឋាន : ផ្ទះលេខ៨៣ ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១៦ ៥៦៥ ៧២៩  លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ហួត គឹមហ៊ាន  ប្រធានសហជីពឯករាជ្យ និងប្រជាធិបតេយ្យ ប្រចាំរោងចក្រ

២- លោក រឿន សារិទ្ធ  អនុប្រធានសហជីពឯករាជ្យ និងប្រជាធិបតេយ្យ

៣- លោក ច័ន្ទ វាសនា  លេខាសហជីពឯករាជ្យ និងប្រជាធិបតេយ្យ

៤- កញ្ញា ទូច ម៉ារ៉ាឌីន  កម្មការិនី

៥- កញ្ញា ទី គឹមហៀង  កម្មការិនី

៦- កញ្ញា ឆេន ផាន  កម្មការិនី

**គ-ឈ្មោះ : សហព័ន្ធសហជីព-សហជីពយុវជនខ្មែរ នៃក្រុមហ៊ុន ក្លូប័ល អាប៉ារែល**

អាសយដ្ឋាន : ភូមិត្រពាំងទូល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្ដាល

លេខទូរស័ព្ទ : ០១២ ២៣៥ ៥៨៦  លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ឈឿង សុធា  លេខាធិការសហជីពយុវជនខ្មែរ ប្រចាំរោងចក្រ

២- លោក ថុន ប៊ុនថា  សមាជិកសហជីពយុវជនខ្មែរ

**ឃ-ឈ្មោះ : សហជីពស្ត្រីកម្ពុជា នៃក្រុមហ៊ុន ក្លូប័ល អាប៉ារែល**

អាសយដ្ឋាន : ភូមិត្រពាំងទូល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្ដាល

លេខទូរស័ព្ទ : ០១២ ២០០ ៧១២  លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ហាម ចន្ថា  ប្រធានសហជីពស្ត្រីកម្ពុជា ប្រចាំរោងចក្រ

២- លោក ស៊ុប ធី  អនុប្រធានសហជីពស្ត្រីកម្ពុជា ប្រចាំរោងចក្រ

៣- លោក សេង ហឿន  លេខាធិការសហជីពស្ត្រីកម្ពុជា ប្រចាំរោងចក្រ

៤- កញ្ញា ស៊ុំ សាម៉េត ប្រធានក្រុមដេរ

៥- កញ្ញា អ៊ុំ លក្ខិណា ប្រធានក្រុមដេរ

៦- កញ្ញា ប៊ុច សារឿន ប្រធានក្រុមដេរ

**ង-ឈ្មោះ : សហជីពសិទ្ធិកម្មករកម្ពុជា នៃក្រុមហ៊ុន គួប័ល អាប៉ារែល**

អាសយដ្ឋាន : ភូមិត្រពាំងទួល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល

លេខទូរស័ព្ទ : ០៩២ ៤១៥ ៧៩០ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិតៈ

១- លោក ជា ប៊ុនធឿន អនុប្រធានសហជីពសិទ្ធិកម្មករកម្ពុជា ប្រចាំរោងចក្រ

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករទាមទារឱ្យក្រុមហ៊ុនផ្តាច់កិច្ចសន្យាចាស់ជាមុនសិន ទើបពួកគាត់ព្រមទៅធ្វើការនៅទីតាំងថ្មី បើមិនដូច្នេះទេ សូមឱ្យក្រុមហ៊ុនយកកម្មករទាំងអស់ (ទាំងអាគារ អា និង បេ) ទៅធ្វើការទីតាំងថ្មី។ ភាគីក្រុមហ៊ុន មិនឯកភាព គឺយកតែកម្មករអាគារ អា ប៉ុណ្ណោះ ទៅធ្វើការនៅទីតាំងថ្មី ហើយអ្វីៗរក្សានៅដដែល។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៣២/០៩ កប/កណ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អាគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់

ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ( វេលាម៉ោង ១៤:០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលពាក្យស្នើសុំប្តូរទីតាំងធ្វើការរបស់ក្រុមហ៊ុន ក្លូប័ល អាប៉ារ៉ែល លីមីតធីត ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០៩។ បន្ទាប់ពីបានទទួលពាក្យស្នើសុំនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ នៅថ្ងៃដដែល ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ លើចំណុចលើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និង ធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ ( វេលាម៉ោង ០២:០០ នាទី រសៀល ) ។ ភាគីទាំងពីរ មានវត្តមាន តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានព្យាយាមធ្វើការផ្សះផ្សារលើចំណុចវិវាទ ០១ ចំណុច នេះ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ។ ដូច្នេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាលើចំណុចវិវាទនេះ ដោយផ្អែកលើភស្តុតាង និង ហេតុផល ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិជូនលោក វី វ៉ាន់ឡូ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ក្លូប័ល អាប៉ារ៉ែល លីមីធីត ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩។

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ក្លូប័ល អាប៉ារ៉ែល លីមីធីត លេខ ១៨១០ ពណ.នគក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧។

៤- លិខិតរបស់ប្រធានក្រុមហ៊ុន កូប៉ល អាប៉ារែល លីមីធីត គោរពជូនបុគ្គលិក-កម្មករ ធ្វើការនៅអាគារ អា ស្តីពីការផ្លាស់ប្តូរទីតាំង របស់បុគ្គលិក-កម្មករ ធ្វើការនៅអាគារ អា ទៅធ្វើការនៅអាគារថ្មីនៃក្រុមហ៊ុន កូប៉ល ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩។

៥- លិខិតរបស់ប្រធានក្រុមហ៊ុន ជីត ថិចថាយ លីមីធីត គោរពជូន បុគ្គលិក-កម្មករ ដែលនឹងត្រូវប្តូរទៅធ្វើការនៅអាគារថ្មី ក្បែរក្រុមហ៊ុន ជីត ស្តីពីការមិនចូលរួមគ្រប់គ្រងលើបុគ្គលិក-កម្មករ របស់ក្រុមហ៊ុន កូប៉ល ដែលនឹងត្រូវប្តូរទីតាំងទៅអាគារថ្មី ក្បែរទីតាំងរោងចក្រ ជីត របស់យើងខ្ញុំ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩។

៦- បទបញ្ជាផ្ទៃក្នុង ក្រុមហ៊ុន ហ្វាស្កា ហ្គាមេន (ខេមបូឌា) អិលធីឌី លេខ ០៧០ ក.ប.វ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤។

៧- សារណាសង្ខេបរបស់ក្រុមហ៊ុន ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩។

៨- លក្ខន្តិកៈរបស់ក្រុមហ៊ុន កូប៉ល អាប៉ារែល លីមីធីត ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៧។

៩- លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជូនទៅក្រុមហ៊ុន ស្តីពីសំណើសុំប្តូរនាមករណ៍ក្រុមហ៊ុន Jusca Garment (Cambodia) Ltd. ទៅជាក្រុមហ៊ុន Global Apparel Limited និងតំកល់លក្ខន្តិកៈថ្មី លេខ ១២៩៥/០៥ គ.វ.ក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៧។

១០- លិខិតរបស់ក្រសួងពាណិជ្ជកម្ម ជូនទៅក្រុមហ៊ុន ស្តីពីករណីសុំផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន និងតំកល់លក្ខន្តិកៈថ្មី លេខ ១៨១០/០៥ ពណ.នតក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧។

១១- កិច្ចសន្យាការងារចំនួន ២ សន្លឹក។

១២- រូបភាពទីតាំងក្រុមហ៊ុន កូប៉ល ថ្មី និង ក្រុមហ៊ុន កូប៉ល ចាស់។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

**-សហជីពខ្មែរ**

១- វិញ្ញាបនប័ត្រចុះបញ្ជិកា សហជីពខ្មែរ នៃរោងចក្រកាត់ដេរ ហ្វាស្កា ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៤។

២- លិខិតតែងតាំង ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨។

**- សហជីពឯករាជ្យ និងប្រជាធិបតេយ្យ**

១- វិញ្ញាបនប័ត្រចុះបញ្ជិកា សហជីពឯករាជ្យ និងប្រជាធិបតេយ្យ នៃរោងចក្រកាត់ដេរ កូប៉ល ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៨។

២- លិខិតជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសផ្លាស់ប្តូរគណៈកម្មការថ្នាក់ដឹកនាំសហជីព សិទ្ធិកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន Global Apparel Limited ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧។

៣- លិខិតរបស់កម្មករ-កម្មការិនី នៅក្នុងក្រុមហ៊ុន គ្លូប័ល បដិសេធមិនព្រមទៅធ្វើការនៅរោងចក្រថ្មី ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៩។

៤- លិខិតរបស់លោកប្រធាននាយកដ្ឋានវិវាទការងារ ជំរាបទៅ ប្រធានសហជីពស្ត្រីកម្ពុជា នៃក្រុមហ៊ុន Global Apparel Limited ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី លេខ ៧៦៩ កប/អក/វក. ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងអាគារងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន គ្លូប័ល អាប៉ារែល លីមីធីត លេខ ០៣២/០៩ កប/កណ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន គ្លូប័ល អាប៉ារែល លីមីធីត ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៤៣ កប/អក/វក/លកអ. ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤២ កប/អក/វក/លកអ. ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន គ្លូប័ល អាប៉ារែល មានទីតាំងស្ថិតនៅភូមិត្រពាំងទូល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល និងមានជូលកម្មករនិយោជិតសរុបចំនួនប្រហែល ៣០០០ នាក់។
- ក្រុមហ៊ុន គ្លូប័ល អាប៉ារែល មានអាគារធ្វើការចំនួន ២ គឺ អាគារ អា និង អាគារ បេ ដែលចែកជាពីរវេន គឺ វេនថ្ងៃ និង វេនយប់។ កម្មករនិយោជិតដែលធ្វើការនៅអាគារ អា វេនថ្ងៃមានចំនួនប្រហែល

6

៨០០ នាក់ និងធ្វើការ វេនយប់ ទាំងអាគារ អា និង អាគារ បេ មានចំនួនសរុបប្រហែល ៦០០ នាក់។ ភាគីកម្មករនិយោជិត និងនិយោជកបញ្ជាក់ថា កម្មករនិយោជិតដែលធ្វើការវេនយប់ តែងតែចល័តការងារពីអាគារ អា ទៅ អាគារ បេ ដូច្នេះពិបាកកំណត់ចំនួនកម្មករក្នុងអាគារនីមួយៗ។ ប៉ុន្តែអាចនិយាយថា កម្មករនិយោជិតធ្វើការវេនយប់នៅ អាគារ អា មានចំនួនប្រហែល ៣០០ នាក់ និងនៅអាគារ បេ មានចំនួនប្រហែល ៣០០ នាក់។

- ភាគីកម្មករនិយោជិត ដែលភាគីនៃដើមបណ្តឹងក្នុងរឿងនេះតំណាងដោយសហជីពចំនួន ៥ គឺ (១) សហជីពយុវជនខ្មែរ, (២)សហជីពសិទ្ធិកម្មករ, (៣)សហជីពស្ត្រីកម្ពុជា, (៤)សហជីពឯករាជ្យនិងប្រជាធិប តេយ្យ និង (៥)សហជីព ខ្មែរ។
- តាមការអះអាងរបស់ភាគីកម្មករនិយោជិត បញ្ជាក់ថា សហជីពយុវជនខ្មែរ សហជីពសិទ្ធិកម្មករ និងសហជីពស្ត្រីកម្ពុជា ស្ថិតនៅក្រោមសហព័ន្ធសហជីពយុវជនខ្មែរ ហើយកម្មករនិយោជិតដែលជាសមាជិកសរុបមានចំនួន ៤៥០ នាក់។
- សហជីពឯករាជ្យ និងប្រជាធិបតេយ្យ មានកម្មករនិយោជិតដែលជាសមាជិកសរុបចំនួន ២៥០ នាក់ និង សហជីពខ្មែរ មានកម្មករនិយោជិតដែលជាសមាជិកសរុបចំនួន ៥៣០ នាក់។
- ភាគីកម្មករនិយោជិត ដែលជាតំណាងសហជីពទាំង ៥ មិនអាចបញ្ជាក់ថា សមាជិករបស់ខ្លួននៅអាគារ អា មានចំនួនប៉ុន្មាននាក់ និង អាគារ បេ មានចំនួនប៉ុន្មាននាក់ទេ។
- តាមការអះអាងរបស់តំណាងភាគីនិយោជក ក្រុមហ៊ុនមានបំណងប្តូរកន្លែងធ្វើការងាររបស់កម្មករនិយោជិតនៅអាគារ អា ទាំងអស់ (ទាំងវេនថ្ងៃ និង វេនយប់) ឱ្យទៅធ្វើការនៅទីតាំងថ្មីនៅអាគារ ដេ អាយធី ជាន់ទី ៣ និង ជាន់ទី ៤ (វេនថ្ងៃតែ មួយ) ព្រោះទីតាំងថ្មីនេះជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ដេ អាយធី ហើយនាយកក្រុមហ៊ុនទាំងពីរជាមនុស្សតែមួយ។ ចំណែកទីតាំងនៅអាគារ អា និង បេ បច្ចុប្បន្ន ក្រុមហ៊ុនជួលពីគេទេ។ ហើយ ការធ្វើការផ្លាស់ប្តូរនេះអាចឱ្យក្រុមហ៊ុនសម្របខ្លួនទៅតាមវិបត្តិសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ន ដើម្បី ជៀសវាងការបិទចក្រ។
- ក្រុមហ៊ុននឹងធ្វើការផ្លាស់ប្តូរវេនរបស់កម្មករនិយោជិតវេនយប់នៅអាគារ អា ទៅវេនថ្ងៃសិន មុននឹងប្តូរពួកគេទៅទីតាំងថ្មី។ និយោជកបញ្ជាក់ទៀតថា ការដូរវេននេះ គឺយោងតាមកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំណុច ៦ ដែលចែងថា "...ម៉ោង និងវេនធ្វើការនឹង ត្រូវផ្លាស់ប្តូរបានទៅតាមកាលៈទេសៈចាំបាច់របស់ក្រុមហ៊ុន។" នៅក្នុងសវនាការ និយោជកបញ្ជាក់ផងដែរថា ក្រុមហ៊ុនមានគម្រោងរៀបចំកម្មករនិយោជិតរបស់ក្រុមហ៊ុនទាំងអស់ ឱ្យមានតែវេនថ្ងៃ។
- ភាគីនិយោជកបញ្ជាក់ថា ចំងាយពីទីតាំងអាគារ អា ទៅ អាគារ ដេ អាយធី មានប្រវែង ៥០០ ម៉ែត្រ ហើយការប្តូរការងារនេះ ក្រុមហ៊ុននៅរក្សាប្រាក់ឈ្នួល និង ផលប្រយោជន៍ផ្សេងៗ របស់កម្មករ

និយោជិត ដែលធ្វើការវេនថ្ងៃ ឱ្យនៅដដែល និងទៅតាមជំនាញរបស់កម្មករនិយោជិតសព្វថ្ងៃ។ ចំណែកកម្មករនិយោជិតដែលធ្វើការវេនយប់ ប្រសិនបើប្តូរមកធ្វើការវេនថ្ងៃ ក្រុមហ៊ុននឹងផ្តល់ ប្រាក់ឈ្នួល និងផលប្រយោជន៍ផ្សេងៗឱ្យកម្មករនិយោជិត ទៅតាមការងារវេនថ្ងៃ ហើយរក្សាជំនាញ របស់កម្មករនិយោជិតនៅដដែលដូចសព្វថ្ងៃ។

- ភាគីនិយោជកបញ្ជាក់ថា មុនការសម្រេចចិត្តប្តូរទីតាំងនេះ ក្រុមហ៊ុនបានធ្វើការប្រជុំនៅថ្ងៃទី ១០ និង ១២ ខែ មករា ឆ្នាំ ២០០៩ ជាមួយប្រធានក្រុមដែលជាប្រធានសហជីពផងដែរ។ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩ ក្រុមហ៊ុនបានជូនដំណឹងទៅកម្មករនិយោជិត ស្តីពីការប្តូរទីតាំងនេះ ប៉ុន្តែកម្មករនិយោជិតមិនព្រម។ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩ ក្រុមហ៊ុនជូនដំណឹងទៅមន្ទីរការងារ ខេត្តកណ្តាល ហើយនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩ ក្រុមហ៊ុនសម្រេចចិត្តប្តូរជាក់ស្តែង ប៉ុន្តែកម្មករនិយោជិតមិនព្រមទៅ។ រហូតមកដល់ថ្ងៃសវនាការនេះ កម្មករនិយោជិតនៅធ្វើការនៅទីតាំងចាស់ អាគារ អា ដដែល។ ក្រុមហ៊ុនស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការសម្រេចរឿងនេះ ឱ្យបានឆាប់ ព្រោះក្រុមហ៊ុនមានបំណងប្តូរការងារកម្មករទៅទីតាំងថ្មី ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន។
- ភាគីកម្មករនិយោជិតប្រកែកមិនព្រមទៅធ្វើការនៅអាគារថ្មីទេ គឺទាមទារនៅធ្វើការក្នុង អាគារ អា ដដែល ដោយមូលហេតុមួយចំនួនដូចជា (១)សុខភាពនិងសុវត្ថិភាពការងារ (អត់មានពេទ្យ បង្គន់មិនគ្រប់គ្រាន់ អត់មានទារកដ្ឋាន ពិបាកហូបបាយ អាគារខ្ពស់ពិបាកឡើង), (២)ឆ្ងាយពីទីតាំងចាស់ប្រហែល ៥០០-៦០០ ម៉ែត្រ, (៣)ពេលធ្វើតេស្តធ្វើការ គឺធ្វើនៅ អាគារ អា, (៤)អាគារថ្មីមានកម្មករពីរក្រុម គឺកម្មករនិយោជិត ក្លូប័ល និង កម្មករនិយោជិត ជេ អាយ ធី ដែលជាហេតុធ្វើឱ្យមានភាពច្រឡំគ្នារវាងកម្មករនិយោជិត នៃរោងចក្រទាំងពីរ។
- ភាគីក្រុមហ៊ុនឆ្លើយតប ចំពោះបញ្ហា ដូចខាងក្រោម:

 ១- សុខភាព និងសុវត្ថិភាពការងារ (អត់មានពេទ្យ បង្គន់មិនគ្រប់គ្រាន់ អត់មានទារកដ្ឋាន ពិបាកហូបបាយ អាគារខ្ពស់ពិបាកឡើង) ក្រុមហ៊ុន នឹងអញ្ជើញសមត្ថកិច្ចទទួលបន្ទុកផ្នែកការងារមកពិនិត្យ ហើយក្រុមហ៊ុននឹងរៀបចំតាមច្បាប់ការងារ។ ក្រុមហ៊ុនបញ្ជាក់ថា សព្វថ្ងៃនៅ អាគារ ជេ អាយ ធី អត់មានពេទ្យ និងទារកដ្ឋានមែន ព្រោះមិនទាន់បានរៀបចំ ដោយសារកម្មករនិយោជិតប្រកែកមិនព្រមទៅធ្វើការនៅ អាគារនោះ។

 ២- ឆ្ងាយពីទីតាំងចាស់ប្រហែល ៥០០-៦០០ ម៉ែត្រ: ក្រុមហ៊ុនយល់ថា ចំងាយនេះមិនឆ្ងាយទេ ព្រោះកម្មករខ្លះដែលធ្វើដំណើរពី កំពង់ស្ពឺ និង ភ្នំប្រសិទ្ធិ អាចដល់ អាគារ ជេ អាយ ធី មុន។

 ៣- ពេលធ្វើតេស្តធ្វើការ គឺធ្វើនៅ អាគារ អា: ក្រុមហ៊ុនយល់ថា ក្រុមហ៊ុនមានសិទ្ធិក្នុងការចាត់ចែង និងប្តូរការងារ របស់កម្មករនិយោជិត។

6

៤- អាគារថ្មីមានកម្មករពីរក្រុមធ្វើឱ្យច្រឡំគ្នារវាងកម្មករនិយោជិត កូប៉ល និង កម្មករនិយោជិត ជេ អាយ ធី: ក្រុមហ៊ុនបញ្ជាក់ថា និង ដាក់ផ្លាកក្រុមហ៊ុន កូប៉ល អាប៉ារ៉ែល នៅជាន់ទី ៣ និង ទី ៤។ ចំណែកប័ណ្ណសំគាល់ខ្លួន គឺ ខុសពីកម្មករនិយោជិត ជេ អាយ ធី។

- មូលហេតុនៃការប្តូរទីតាំង និយោជកលើកឡើងថា ទាក់ទងនឹងបញ្ហាសេដ្ឋកិច្ច ដោយបច្ចុប្បន្នក្រុមហ៊ុនជួលអាគាររបស់គេ ដើម្បីដំណើរការអាជីវកម្ម ហើយទីតាំងថ្មីនេះ ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ដូចនេះក្រុមហ៊ុនអាចកាត់បន្ថយថ្លៃជួលអាគារ ដែលជាចំណែកមួយនៃការ កាត់បន្ថយថ្លៃដើមដើម្បីធានានិរន្តរភាព។ បន្ថែមពីនេះ ក្រុមហ៊ុនបញ្ជាទិញមួយ បានដាក់ការបញ្ជាទិញ របស់ខ្លួននៅទីតាំងថ្មី ដើម្បីធ្វើឱ្យប្រសើរឡើង ក្នុងការគ្រប់គ្រង និងកាត់បន្ថយចំណាយរដ្ឋបាលលើការគ្រប់គ្រងទីតាំងពីរកន្លែង មកនៅមួយកន្លែងវិញ។ ជាមួយនេះផងដែរ នៅទីតាំងថ្មីអាចកាត់បន្ថយថ្លៃដើម និងបង្កើនផលិតភាព ដោយនៅក្បែរទីតាំងថ្មីមានផ្តល់សេវាបោះពុម្ព និងប៉ាក់ ដែលជាការងារស្រួលដល់ក្រុមហ៊ុនក្នុងការដឹកជញ្ជូន និងការទំនាក់ទំនង ដែលជាចំណែកមួយក្នុងការកាត់បន្ថយថ្លៃដើម។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបង្គាប់ឱ្យក្រុមហ៊ុនផ្តល់ឯកសារមួយចំនួន ដែលក្រុមហ៊ុនយល់ថា ចាំបាច់ដើម្បីគាំទ្រការអះអាងរបស់ខ្លួន។ ក្រុមហ៊ុនបានដាក់ឯកសារ មកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ តាមកាលកំណត់។

**ហេតុផលនៃសេចក្តីសម្រេចៈ**

ក្នុងករណីនេះ កម្មករនិយោជិតទាមទារនៅធ្វើការនៅទីតាំង អាគារ អា ដដែល ហើយប្រកែកមិនព្រមទៅធ្វើការ នៅទីតាំងថ្មីនៅ អាគារ ជេ អាយ ធី។ ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមហ៊ុនមានសិទ្ធិក្នុងការប្តូរកន្លែងធ្វើការរបស់កម្មករពី អាគារ អា ទៅ អាគារ ជេ អាយ ធី ដែរ ឬទេ?

មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា *"សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុម ធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និង ដឹកនាំនៃនិយោជក ។..."*

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារ ខាងលើនេះ មានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ល្គិកណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៦២/០៦-ឃ្វីក ស៊ូ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៥ លេខ ១០៨/០៦-ទ្រីនុងហ្គាល កូមារ៉ា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និង លេខ ៣៣/០៧-ហ្គោល ហ្វេម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ លេខ ១០៦/០៧*

*-អ៊ីម និង វ៉ៅ ទី៣ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ លេខ៨៤/០៨ - ទ្រីនុងហ្គាល់ គូមារ៉ា ហេតុផលនៃ សេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ១៤១/០៨ -ប៊្លូមថេម ហេតុផលនៃ សេចក្តីសម្រេចចំណុចវិវាទទី១* ) ។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជក មានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន រួមមានការផ្ទេរកម្មករនិយោជិតពីកន្លែងមួយ ទៅកន្លែងមួយ ប៉ុន្តែនិយោជកត្រូវគោរព នូវលក្ខខណ្ឌមួយចំនួន ដូចជា : (១)- មិនកាត់ប្រាក់ឈ្នួល (២)-មិនផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ (៣)-មិនប្តូរវេនការងារ ពីថ្ងៃទៅយប់ ឬពីយប់មកថ្ងៃ (៤)-មិនផ្លាស់ប្តូរខុស ពីជំនាញខ្លាំងពេក។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ១៥៣/០៨-ប៉ៃតិច ហ្គាមេន លេខ១៣៧/០៧-អ៊ីម កី អេ លេខ៨៤/០៨-ទ្រីនុងហ្គាល់ គូមារ៉ា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ១៧/០៣ និង១៨/០៣-ហ្វូ ហ៊ីង ហេតុផលនៃ សេចក្តីសម្រេច ចំណុចវិវាទទី១*) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាល ក្នុងសំណុំរឿងខាងលើដែរ គឺ ភាគីនិយោជកមានសិទ្ធិក្នុងការចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុនដូចជា ការផ្ទេរកម្មករនិយោជិតពីកន្លែងមួយទៅកន្លែងមួយ ហើយនិងការផ្តល់ឱ្យនូវលក្ខខណ្ឌមួយចំនួនដូចជា : (១)- មិនកាត់ប្រាក់ឈ្នួល (២)-មិនផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ (៣)-មិនប្តូរវេនការងារពីថ្ងៃទៅយប់ ឬពីយប់មកថ្ងៃ (៤)-មិនផ្លាស់ប្តូរខុសពីជំនាញខ្លាំងពេក។ នេះមានន័យថា និយោជកត្រូវគោរពចំពោះលក្ខខណ្ឌទាំងបួន នៅពេលធ្វើការផ្លាស់ប្តូរការងារកម្មករនិយោជិត ដើម្បីឱ្យការផ្លាស់ប្តូរនោះ ធ្វើឡើងឱ្យស្របច្បាប់ និងមានលក្ខណៈសមរម្យ។ ក្នុងករណីនេះ ក្រុមហ៊ុនមានបំណងធ្វើការប្តូរកន្លែងធ្វើការរបស់កម្មករនិយោជិតពី អាគារ អា ទាំងអស់ទៅអាគារថ្មី (ជេ អាយ ធី) ហើយមានការផ្លាស់ប្តូរចំពោះកម្មករ អាគារ អា ទាំងអស់ ទាំងកម្មករនិយោជិតដែលធ្វើការវេនថ្ងៃនៅអាគារ អា និង កម្មករនិយោជិតដែលធ្វើការវេនយប់ ដែលត្រូវប្តូរទៅវេនថ្ងៃនៅ អាគារ អា មុននឹងប្តូរទៅអាគារថ្មី (ជេ អាយ ធី)។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញា កណ្តាលធ្វើការពិចារណាថា តើការផ្លាស់ប្តូរនេះ គោរពល័ក្ខខ័ណ្ឌទាំងបួន ឬទេ ហើយមានផលប៉ះពាល់អ្វីខ្លះ?

លក្ខខណ្ឌទី(១)- មិនកាត់ប្រាក់ឈ្នួល : ដោយយោងតាមអង្គហេតុខាងលើ និយោជកសន្យាថា នឹងរក្សាប្រាក់ឈ្នួលឱ្យនៅដដែល។ ដូច្នេះ ការប្តូរវេនដែលនឹងធ្វើឡើងនេះ មិនមានការប៉ះពាល់ប្រាក់ឈ្នួលទេ។ មានន័យថា លក្ខខណ្ឌទី(១) នេះ ត្រូវបានបំពេញ។

លក្ខខណ្ឌទី(២)-មិនផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ: ដោយយោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល រកឃើញថា ចំងាយពីអាគារអា ទៅអាគារ ជេ អាយ ធី មានចំងាយប្រហែល ៥០០-៦០០ ម៉ែត្រ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំងាយនេះមិនមែនជាចំងាយដែលឆ្ងាយពេកទេ។ ប៉ុន្តែវាអាចទាក់ទងនឹងពេលវេលា មកដល់កន្លែងធ្វើការរបស់កម្មករ។ ដូច្នេះនៅពេលមានការផ្លាស់ប្តូរ និយោជកត្រូវធ្វើការ

សាកល្បងមួយសប្តាហ៍មើលសិន ដើម្បីឱ្យកម្មករនិយោជិតមានទម្លាប់ជាមួយទីតាំងថ្មី ក្នុងអាគារចំណាយពេលវេលារបស់ពួកគេមកកន្លែងធ្វើការ។ ដូច្នេះការប្តូរវេនដែលនឹងធ្វើឡើងនេះ មិនមានផលប៉ះពាល់ខ្លាំងទេ ដល់កម្មករនិយោជិត។ មានន័យថា លក្ខខណ្ឌទី(២) នេះ ត្រូវបានបំពេញ។

លក្ខខណ្ឌទី(៣)-មិនប្តូរវេនការងារពីថ្ងៃទៅយប់ ឬពីយប់ មកថ្ងៃ: ដោយយោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល រកឃើញថា ការផ្លាស់ប្តូរនេះ គឺក្រុមហ៊ុនបានផ្លាស់ប្តូរការងារកម្មករនៅ អាគារ អា វេនថ្ងៃ ទៅអាគារ ជេ អាយធី នៅវេនថ្ងៃដែរ។ ដូច្នេះមិនមានផលប៉ះពាល់នៃពេលវេលាធ្វើការទេ។ ចំពោះការផ្លាស់ប្តូរកម្មករធ្វើការវេនយប់ ដែលដូរមក អាគារ អា វេនថ្ងៃ ហើយបានផ្លាស់ប្តូរកម្មករនោះ បន្តទៅអាគារ ជេ អាយ ធី នោះជារឿងចាត់ចែងរបស់ក្រុមហ៊ុន ហើយប្រសិនបើ កម្មករនិយោជិតណាយល់ថា សិទ្ធិរបស់ខ្លួនត្រូវបានបំពាន ពួកគេមានសិទ្ធិតវ៉ាតាមច្បាប់។ ដូច្នេះការប្តូរវេន ដែលនឹងធ្វើឡើងនេះ មិនមានផលប៉ះពាល់ពីវេនការងារពីថ្ងៃទៅយប់ទេ ឬផ្ទុយទៅវិញ។ មានន័យថា លក្ខខណ្ឌទី(៣) នេះ ត្រូវបានបំពេញ។

លក្ខខណ្ឌទី(៤)-មិនផ្លាស់ប្តូរខុសពីជំនាញខ្លាំងពេក: ដោយយោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល រកឃើញថា ការផ្លាស់ប្តូរនេះ មិនមានការប្តូរជំនាញកម្មករទេ។ ដូច្នេះការប្តូរវេនដែល នឹងធ្វើឡើងនេះ មិនមានផលប៉ះពាល់ជំនាញរបស់ម្មករនិយោជិតទេ។ មានន័យថា លក្ខខណ្ឌទី(៤) - ត្រូវបាន បំពេញ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានសិទ្ធិផ្លាស់ប្តូរទីតាំងកម្មករនិយោជិត ដែលធ្វើការវេនថ្ងៃនៅ អាគារ អា ទៅធ្វើការ នៅទីតាំងថ្មីនៅវេនថ្ងៃ។

ចំពោះកម្មករនិយោជិតដែលធ្វើការវេនយប់ ហើយត្រូវប្តូរទៅវេនថ្ងៃនៅ អាគារ អា ទីតាំងចាស់ ដែលនឹងត្រូវប្តូរទៅទីតាំងថ្មីវិញ យោងតាមមាត្រា ១៤៤ ថ្មី នៃច្បាប់ការងារឆ្នាំ១៩៩៧ វិសោធនកម្មឆ្នាំ២០០៧ ចែងថា "...*ក្រៅពីការងារបន្តបន្ទាប់ដែលក្រុមកម្មករផ្លាស់វេនគ្នាធ្វើការជូនថ្ងៃ ជូនយប់ ការងារនៃសហគ្រាស អាចមានធ្វើមួយផ្នែកនៃពេលយប់ជានិច្ច។ ការងារពេលយប់ត្រូវឱ្យឈ្នួលតាមអត្រា ១៣០ % (មួយរយសាមសិបភាគរយ) នៃប្រាក់ឈ្នួលធ្វើការពេលថ្ងៃ។* " បើពិនិត្យលើលក្ខខណ្ឌទាំងបួន មានប៉ះពាល់លើ (១)-ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលធ្វើការវេនយប់ ហើយត្រូវប្តូរទៅវេនថ្ងៃនៅ អាគារ អា ព្រោះពួកគេនឹងត្រូវប្តូរទៅធ្វើការវេនថ្ងៃ ដែលពួកគេនឹងបានប្រាក់ឈ្នួល ៣០ ភាគរយ តិចជាងប្រាក់ឈ្នួលការងារវេនយប់។ ប៉ុន្តែហេតុផលដែលនាំឱ្យពួកគេបានប្រាក់ឈ្នួល ៣០ ភាគរយ តិចជាងប្រាក់ឈ្នួលពួកគេធ្លាប់បានដោយសារតែពួកគេផ្លាស់ប្តូរវេនពីវេនយប់ទៅវេនថ្ងៃមិនមែនដោយនិយោជកកាត់នោះទេ។

ការផ្លាស់ប្តូរទីតាំងនេះប៉ះពាល់លើវេនការងាររបស់កម្មករនិយោជិតវេនយប់ ដែលត្រូវទៅធ្វើការវេនថ្ងៃវិញនៅទីតាំងថ្មី ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងពិចារណាថា តើនិយោជកមានហេតុផលសមរម្យក្នុងការផ្លាស់ប្តូរវេនការងារ និងប្តូរទីតាំងឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជក មានសិទ្ធិក្នុងការផ្លាស់ប្តូរវេនការងារ របស់កម្មករនិយោជិត (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥៣/០៨-យ៉ុង វ៉ា ទី១ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤ និងលេខ ៥៤/០៦-ប្រាយ ស្កាយ* )។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញដូចក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗដែរ។

នៅក្នុងសំណុំរឿងនេះ និយោជកបានលើកឡើងពីហេតុផលក្នុងការផ្លាស់ប្តូរវេនការងារ និងការផ្លាស់ប្តូរទីតាំងនេះថា ដោយសារបញ្ហាសេដ្ឋកិច្ច ដោយបច្ចុប្បន្នក្រុមហ៊ុនជួលអាគាររបស់គេ ដើម្បីដំណើរការអាជីវកម្ម ហើយទីតាំងថ្មី ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ដូចនេះក្រុមហ៊ុនអាចកាត់បន្ថយថ្លៃជួលអាគារ ដែលជាចំណែកមួយនៃការកាត់បន្ថយថ្លៃដើម ដើម្បីធានានិរន្តរភាព។ ហើយក្រុមហ៊ុននឹងរៀបចំឱ្យមានតែការងារវេនថ្ងៃទេ ទាំងនៅអាគារចាស់ និងនៅអាគារថ្មី។ លើសពីនេះទៀត ក្រុមហ៊ុនលើកឡើងថា ក្រុមហ៊ុនបញ្ជាទិញមួយ បានដាក់ការបញ្ជាទិញរបស់ខ្លួននៅទីតាំងថ្មី ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការគ្រប់គ្រង និងកាត់បន្ថយចំណាយរដ្ឋបាលលើការគ្រប់គ្រងទីតាំងពីរកន្លែងមកនៅមួយកន្លែងវិញ។ ជាមួយនេះផងដែរ នៅទីតាំងថ្មី អាចកាត់បន្ថយថ្លៃដើម និងបង្កើនផលិតភាព ដោយនៅក្បែរទីតាំងថ្មីមានផ្តល់សេវាបោះពុម្ព និងប៉ាក់ ដែលជាការងារស្រួលដល់ក្រុមហ៊ុនក្នុងការដឹកជញ្ជូន ការទំនាក់ទំនង ដែលជាចំណែកមួយក្នុងការកាត់បន្ថយថ្លៃដើម។ ចំណែកឯកម្មករនិយោជិតវិញមិនចង់ទៅធ្វើការ នៅទីតាំងថ្មី ដោយលើកហេតុផលថា មានបញ្ហាសុខភាព និងសុវត្ថិភាពការងារ ពេលធ្វើតេស្តធ្វើការ គឺធ្វើនៅ អាគារ អា ចង់ធ្វើការនៅអាគារ អា ដដែល អាគារថ្មីមានកម្មករពីរក្រុម ធ្វើឱ្យច្រឡំគ្នារវាងកម្មករនិយោជិត ក្លូប៊ល និង កម្មករនិយោជិត ជេ អាយ ធី ប៉ុន្តែកម្មករនិយោជិតមិនមានហេតុផលគ្រប់គ្រាន់លើបញ្ហានេះទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានហេតុផលសមរម្យក្នុងការផ្លាស់ប្តូរវេនការងារ និងប្តូរទីតាំង។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់កម្មករនិយោជិត ដែលប្រកែកមិនព្រមទៅធ្វើការ នៅទីតាំងថ្មី នៅ អាគារ ជេ អាយ ធី។

## <u>សម្រេច និង បង្គាប់</u>

- បដិសេធការទាមទាររបស់ កម្មករនិយោជិត ដែលប្រកែកមិនព្រមទៅធ្វើការ នៅទីតាំងថ្មីនៅអាគារ ជេ អាយ ធី។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងអាគារងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុំ សុន្ធី**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ----------------------------------------

ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ០៨/០៩_ក្លូប័ល អាប៉ារែល

## យោបល់ជំទាស់ទៅនឹងចំណុចវិវាទទី១

យោងតាមប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខ្ញុំ **លីម សុវណ្ណា** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងចំណុចវិវាទទី ១ នៃសេចក្តីបង្គាប់ លេខ ០៨/០៩ ក្រុមហ៊ុន ក្លូប័ល អាប៉ារែល ដូចតទៅ :

**អង្គហេតុ : ចំណុចវិវាទទី ១ : កម្មករនិយោជិតទាមទារធ្វើការនៅក្នុងអគារ អា នៃក្រុមហ៊ុនក្លូប័ល អាប៉ារែល ដដែល ។**

ចំពោះអង្គហេតុក្នុងចំណុចវិវាទនេះ ខ្ញុំសូមជំទាស់ត្រង់ចំណុចដែលទទួលស្គាល់ថា *"ក្រុមហ៊ុនប្តូរកម្មករវេនយប់ ដែលធ្វើការនៅក្នុងអគារ អា ទៅវេនថ្ងៃរួចហើយ ទើបធ្វើការផ្លាស់ប្តូរទៅទីតាំងថ្មី "* ។ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងសវនាការ ភាគីកម្មករនិយោជិត និងភាគីនិយោជកបានលើកឡើងស្របគ្នាថា "អគារ អា សព្វថ្ងៃ នៅតែមានកម្មករវេនយប់ធ្វើការដដែល ។ និយោជកនឹងប្តូរកម្មករវេនយប់ ទៅធ្វើការនៅវេនថ្ងៃវិញ នៅពេលដែលផ្លាស់ប្តូរទីតាំងថ្មីនៅអគារ ដេ អាយ ធី ។ ខាងក្រោមនេះ គឺជាអង្គហេតុ ដែលខ្ញុំយល់ស្រប :

- ក្រុមហ៊ុន ក្លូប័ល អាប៉ារែល មានទីតាំងស្ថិតនៅភូមិត្រពាំងទួល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល និង មានជួលកម្មករនិយោជិតសរុបចំនួនប្រហែល ៣០០០ នាក់ ។
- ក្រុមហ៊ុន ក្លូប័ល អាប៉ារែល មានអាគារធ្វើការចំនួន ២ គឺ អគារ អា និង អគារ បេ ដែលចែកជាពីរវេន គឺ វេនថ្ងៃ និងវេនយប់ ។ កម្មករនិយោជិត ដែលធ្វើការនៅ អាគារ អា វេនថ្ងៃមានចំនួនប្រហែល ៨០០ នាក់ និងធ្វើការវេនយប់មានចំនួនសុរបប្រហែល ៦០០ នាក់ ។ ភាគីកម្មករនិយោជិត និងនិយោជកបញ្ជាក់ថា កម្មករនិយោជិតដែលធ្វើការវេនយប់តែងតែចល័តការងារពីអគារ អា ទៅអគារ បេ ដូច្នេះពិបាកកំណត់ ចំនួនកម្មករក្នុងអគារនីមួយៗ ។
- ភាគីកម្មករនិយោជិត ដែលជាភាគីនៃដើមបណ្តឹងក្នុងរឿងនេះ តំណាងដោយសហជីពចំនួន ៥ គឺ សហជីពយុវជនខ្មែរ សហជីពសិទ្ធិកម្មករ សហជីពស្ត្រីកម្ពុជា សហជីពឯករាជ្យ និងប្រជាធិបតេយ្យ និង សហជីពខ្មែរ ។
- តាមការអះអាងរបស់ភាគីកម្មករនិយោជិតបញ្ជាក់ថា សហជីពយុវជនខ្មែរ និងសហជីពសិទ្ធិកម្មករ សហជីពស្ត្រីកម្ពុជា ស្ថិតនៅក្រោមសហព័ន្ធសហជីពយុវជនខ្មែរ ហើយកម្មករនិយោជិតដែលជាសមាជិកសរុបមានចំនួន ៤៥០ នាក់ ។
- សហជីពឯករាជ្យ និងប្រជាធិបតេយ្យ មានកម្មករនិយោជិតដែលជាសមាជិកសរុបចំនួន ២៥០ នាក់

និង សហជីពខ្មែរ មានកម្មករនិយោជិតដែលជាសមាជិកសរុបចំនួន ៩៣០ នាក់។

- ភាគីកម្មករនិយោជិត ដែលជាតំណាងសហជីពទាំង ៥ មិនអាចបញ្ជាក់ថា សមាជិករបស់ខ្លួននៅអគារ អា មានចំនួនប៉ុន្មាននាក់ និងអគារ បេ មានចំនួនប៉ុន្មាននាក់ទេ។
- តាមការអះអាងរបស់តំណាងភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមានបំណងប្តូរកន្លែងធ្វើការងាររបស់កម្មករនិយោជិតនៅអគារ អា ទាំងវេនថ្ងៃ និងវេនយប់ ឱ្យទៅធ្វើការនៅទីតាំងថ្មីនៅអគារ ដេ អាយ ធី ជាន់ទី ៣ និង ជាន់ទី ៤ (វេនថ្ងៃតែមួយ) ព្រោះទីតាំងថ្មីនេះ ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ដេ អាយ ធី ហើយ នាយកក្រុមហ៊ុនទាំងពីរជាមនុស្សតែមួយ។ ចំណែកទីតាំង បច្ចុប្បន្ននៅអគារ អា និង បេ ក្រុមហ៊ុនជួលពីគេទេ។ ភាគីនិយោជកបញ្ជាក់ថា ចំងាយពីទីតាំងអគារ អា ទៅអគារ ដេ អាយ ធី មានចំងាយ ៥០០ ម៉ែត្រ។ ភាគីនិយោជកបញ្ជាក់ថា ការប្តូរការងារនេះក្រុមហ៊ុននៅរក្សាប្រាក់ឈ្នួល និងផលប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិត ដែលធ្វើការវេនថ្ងៃឱ្យនៅដដែល ហើយទៅតាមជំនាញរបស់កម្មករនិយោជិតសព្វថ្ងៃ។ ចំណែកកម្មករនិយោជិត ដែលធ្វើការវេនយប់ ដែលប្តូរមកធ្វើការវេនថ្ងៃ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឈ្នួល និងផលប្រយោជន៍ដូចឱ្យកម្មករនិយោជិតទៅតាមការងារវេនថ្ងៃ ហើយរក្សាជំនាញរបស់ កម្មករនិយោជិតនៅដដែល សព្វថ្ងៃ។
- ភាគីកម្មករនិយោជិតប្រកែកមិនព្រមទៅធ្វើការនៅអគារថ្មីទេ គឺទាមទារនៅធ្វើការក្នុងអគារ អា ដដែល ដោយមូលហេតុមួយចំនួនដូចជា (១)សុខភាព និងសុវត្ថិភាពការងារ (អត់មានពេទ្យ បង្គន់មិនគ្រប់គ្រាន់ អត់ទារកដ្ឋាន ពិបាកហូបបាយ អគារខ្ពស់ពិបាកឡើង), (២)ឆ្ងាយពីទីតាំងចាស់ប្រហែល៥០០-៦០០ម៉ែត្រ, (៣)ពេលធ្វើតេស្តធ្វើការគឺធ្វើនៅអគារ អា, (៤)អគារថ្មីមានកម្មករពីរក្រុមធ្វើឱ្យច្រឡំគ្នារវាង កម្មករនិយោជិត គួប៉េល និង កម្មករនិយោជិត ដេ អាយ ធី។

➢ ភាគីក្រុមហ៊ុនឆ្លើយតបចំពោះបញ្ហា ដូចខាងក្រោម៖

(១) សុខភាព និងសុវត្ថិភាពការងារ (អត់មានពេទ្យ បង្គន់មិនគ្រប់គ្រាន់ អត់ទារកដ្ឋាន ពិបាកហូបបាយ អគារខ្ពស់ពិបាកឡើង) ក្រុមហ៊ុននឹងអញ្ជើញសមត្ថកិច្ចទទួលបន្ទុកផ្នែកការងារមកពិនិត្យ ហើយក្រុមហ៊ុននឹងរៀបចំតាមច្បាប់ការងារ។ ក្រុមហ៊ុនបញ្ជាក់ថា សព្វថ្ងៃនៅអគារ ដេ អាយ ធី អត់មានពេទ្យ និងទារកដ្ឋានមែន ព្រោះមិនទាន់បានរៀបចំដោយសារ កម្មករនិយោជិតប្រកែកមិនព្រមទៅធ្វើការនៅអគារនោះ។

(២)ឆ្ងាយពីទីតាំងចាស់ប្រហែល ៥០០-៦០០ ម៉ែត្រ៖ ក្រុមហ៊ុនយល់ថា ចំងាយនេះមិនឆ្ងាយទេ ព្រោះកម្មករ ខ្លះដែលធ្វើដំណើរពីកំពង់ស្ពឺ និងភ្នំប្រសិទ្ធិអាចដល់អគារ ដេ អាយ ធី មុន។

(៣)ពេលធ្វើតេស្តធ្វើការគឺធ្វើនៅអគារ អា៖ ក្រុមហ៊ុនយល់ថា ក្រុមហ៊ុនមានសិទ្ធិក្នុងការចាត់ចែង និងប្តូរការងាររបស់កម្មករនិយោជិត។

(៤) អគារថ្មីមានកម្មករពីរក្រុមធ្វើឱ្យច្រឡំគ្នារវាងកម្មករនិយោជិត ក្លូប័ល និងកម្មករនិយោជិត ជេ អាយ ធី ក្រុមហ៊ុនបញ្ជាក់ថា និង ដាក់ផ្លាកក្រុមហ៊ុន ក្លូប័ល អាប៉ារ៉ែល នៅជាន់ទី ៣ និង ទី ៤។ ចំណែកប័ណ្ណសំគាល់ខ្លួនគឺខុសពីកម្មករនិយោជិត ជេ អាយ ធី។

- មូលហេតុនៃការប្តូរទីតាំង និយោជកលើកឡើងថា ទាក់ទងនឹងបញ្ហាសេដ្ឋកិច្ច ដោយបច្ចុប្បន្នក្រុមហ៊ុនជួលអគាររបស់គេ ដើម្បីដំណើរការអាជីវកម្ម ហើយទីតាំងថ្មី ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ដូចនេះក្រុមហ៊ុនអាច កាត់បន្ថយថ្លៃជួលអគារ ដែលជាចំណែកមួយនៃការកាត់បន្ថយថ្លៃដើម ដើម្បីធានានិរន្តរភាព។ ក្រុមហ៊ុនបញ្ជាទិញមួយបានដាក់ការបញ្ជាទិញរបស់ខ្លួននៅទីតាំងថ្មី ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងការគ្រប់គ្រង និង កាត់បន្ថយចំណាយរដ្ឋបាលលើការគ្រប់គ្រងទីតាំងពីរកន្លែងមកនៅមួយកន្លែងវិញ។ ជាមួយនេះផងដែរ នៅទីតាំងថ្មីអាចកាត់បន្ថយថ្លៃដើម និងបង្កើនផលិតភាព ដោយនៅក្បែរទីតាំងថ្មីមានផ្តល់សេវាបោះពុម្ព និងប៉ាក់ ដែលជាការងារស្រួលដល់ក្រុមហ៊ុនក្នុងការដឹកជញ្ជូនការទំនាក់ទំនង ដែលជាចំណែកមួយក្នុងការកាត់បន្ថយថ្លៃដើម។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យក្រុមហ៊ុនផ្តល់ឯកសារមួយចំនួន ដែលក្រុមហ៊ុនយល់ថាចាំបាច់ដើម្បីគាំទ្រការអះអាងរបស់ខ្លួន។ ក្រុមហ៊ុនបានដាក់ឯកសារមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០៩ តាមកាលកំណត់។

## ហេតុផលនៃសេចក្តីសម្រេចៈ

ក្នុងករណីនេះកម្មករនិយោជិតទាមទារនៅធ្វើការនៅទីតាំងអគារ អា ដដែល ហើយប្រកែកមិនព្រមទៅធ្វើការនៅទីតាំងថ្មីនៅអគារ ជេ អាយ ធី។ ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមហ៊ុនមានសិទ្ធិក្នុងការប្តូរកន្លែងធ្វើការរបស់កម្មករពីអគារ អា ទៅអគារ ជេ អាយ ធី ដែរ ឬទេ? ។ ដូច្នេះខ្ញុំសូមជំទាស់ទៅនឹងហេតុផលនៃសេចក្តីសំរេច ក្នុងសេចក្តីបង្គាប់លេខ ០៨/០៩-ក្លូប័ល អាប៉ារ៉ែល ដែលបានបកស្រាយ និងផ្តល់ហេតុផលលើសពីការប្តឹងទាមទាររបស់កម្មករនិងយោជិត ហើយបានទាំងបកស្រាយថា ការប្តូរកម្មករវេនយប់ទៅធ្វើការវេនថ្ងៃនៅទីតាំងថ្មី គឺសមស្របតាមច្បាប់ និងសមរម្យទៅវិញ។ ខ្ញុំយល់ថា ក្នុងសំណុំរឿងនេះគប្បីបកស្រាយ និងសំរេចត្រឹមតែបណ្តឹងរបស់ភាគីកម្មករនិយោជិត នៅធ្វើការនៅទីតាំងអគារ អា ដដែល ហើយប្រកែកមិនព្រមទៅធ្វើការនៅទីតាំងថ្មីនៅអគារ ជេ អាយ ធី ថាតើត្រឹមត្រូវតាមច្បាប់ដែរ ឬទេ? តាមច្បាប់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យ និងសំរេចត្រឹមបណ្តឹងទាមទាររបស់ភាគីកម្មករនិយោជិត ដែលមាននៅក្នុងកំណត់ហេតុមិនសះជា ឬបញ្ហានៃវិវាទ ដែលកើតឡើងក្រោយការធ្វើកំណត់ហេតុ ហើយដែលជាផលវិបាកផ្ទាល់នៃវិវាទប៉ុណ្ណោះ។ ការសំរេចលើការទាមទារ គឺមិនសមស្របតាមច្បាប់ទេ។ ជាពិសេសខ្ញុំជំទាស់ទៅលើការទទួលស្គាល់ថាការផ្លាស់ប្តូរកម្មករនិយោជិត ដែលធ្វើការវេនយប់ឱ្យទៅធ្វើការវេនថ្ងៃនៅទីតាំងថ្មីវិញ គឺស្របច្បាប់ និងសមរម្យ

នោះទាំងស្រុង។ ពីព្រោះការប្តូរវេននេះ បណ្តាលឱ្យកាត់បន្ថយប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលជាការបំពានលើល័ក្ខខ័ណ្ឌពីរក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបួនដូចការបកស្រាយខាងក្រោម។ ខាងក្រោមនេះជាហេតុផលដែលនៅយល់ឃើញថា ត្រឹមត្រូវ :

មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា *"សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុម ធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និង ដឹកនាំនៃនិយោជក ។..."*

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារខាងលើនេះមានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ល្គិកណាសិទ្ធិនេះត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៦២/០៦-ឃើកស៊ូ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៥ លេខ ១០៨/០៦-ទ្រីនុងហ្គាល កូមារ៉ា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ៣៣/០៧-ហ្គោល ហ្វេម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ លេខ ១០៦/០៧-អ៊ីម និង វ៉េ ទី៣ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣ លេខ៨៤/០៨-ទ្រីនុងហ្គាល់ កូមារ៉ា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ១៤១/០៨-ប៊ួមថេម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១*)។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន រួមមានការផ្ទេរកម្មករនិយោជិតពីកន្លែងមួយ ទៅកន្លែងមួយ ប៉ុន្តែនិយោជកត្រូវគោរពនូវលក្ខខណ្ឌ មួយចំនួនដូចជា : (១)- មិនកាត់ប្រាក់ឈ្នួល (២)-មិនផ្លាស់ប្តូរកម្មករ និយោជិតទៅកន្លែងឆ្ងាយ (៣)-មិនប្តូរវេនការងារពីថ្ងៃទៅយប់ ឬពីយប់មកថ្ងៃ (៤)-មិនផ្លាស់ប្តូរខុស ពីជំនាញខ្លាំងពេក។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ១៥៣/០៨-ហៃតិច ហ្គាមេន លេខ ១៣៧/០៧-អឹម គី អេ លេខ៨៤/០៨-ទ្រីនុងហ្គាល់ កូមារ៉ា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ១៧/០៣ និង១៨/០៣-ហ៊ូ ហ៊ីង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទ ទី១*)។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ គឺភាគីនិយោជកមានសិទ្ធិក្នុងការចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុនដូចជា ការផ្ទេរកម្មករនិយោជិតពីកន្លែងមួយទៅកន្លែងមួយ ហើយនិងការផ្តល់ឱ្យនូវល័ក្ខខ័ណ្ឌមួយចំនួនដូចជា : (១)- មិនកាត់ប្រាក់ឈ្នួល (២)-មិនផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ (៣)-មិនប្តូរវេនការងារពីថ្ងៃទៅយប់ ឬពីយប់មកថ្ងៃ (៤)-មិនផ្លាស់ប្តូរខុសពីជំនាញខ្លាំងពេក។ នេះមានន័យថា និយោជកត្រូវគោរពចំពោះល័ក្ខខណ្ឌទាំងបួននៅពេលធ្វើការផ្លាស់ប្តូរការងារកម្មករនិយោជិត ដើម្បីឱ្យការផ្លាស់ប្តូរនោះ ធ្វើឡើងឱ្យស្របច្បាប់ និងមានលក្ខណៈ

សមរម្យ។ ហើយក្នុងករណីផ្ទេរកម្មករនោះ ប៉ះពាល់ដល់ចំណុចណាមួយនៃល័ក្ខខ័ណ្ឌទាំងបួនខាងលើចាត់ទុកថា និយោជកបំពានលើល័ក្ខខ័ណ្ឌនៃកិច្ចសន្យាការងារ។ នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតទាមទារមិនឱ្យ និយោជកផ្លាស់ប្តូរកម្មករអគារ អា ទៅធ្វើការនៅទីតាំងថ្មី អគារ ជេ អាយ ធី ដោយមិនបានទាមទារ ឬតវ៉ាលើ ការបំពានល័ក្ខខ័ណ្ឌនៃកិច្ចសន្យាការងារ ដែលកើតចេញពីការផ្លាស់ប្តូរទីតាំងការងារនោះទេ។ ក្រុមប្រឹក្សាអាជ្ញា កណ្តាលគប្បីពិចារណាតែត្រឹមសិទ្ធិចាត់ចែង ផ្លាស់ប្តូរទីតាំងការងារតាមបណ្តឹងទាមទាររបស់ភាគីកម្មករនិយោជិត តែប៉ុណ្ណោះ។ ក្នុងករណីផ្លាស់ប្តូរទីតាំងនេះ ប៉ះពាល់ដល់ល័ក្ខខ័ណ្ឌនៃកិច្ចសន្យាការងារ ឬល័ក្ខខ័ណ្ឌការងារ ភាគី កម្មករនិយោជិតមានសិទ្ធិតវ៉ាតាមច្បាប់។

ភ្នំពេញ ,ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

អាជ្ញាកណ្តាល

**លីវ សុវណ្ណា**